# កត់ចំណាំនៅប្រក្រតិទិនរបស់អ្នក

# គឺជាថ្ងៃដើរទៅសាលា ជាអន្តរជាតិ

សូមជំរាបមកដល់មាតាបិតា ៖

យើងមានក្តីសោមនស្សប្រកាសថា សាលារបស់យើងកំពុងតែមានការចូលរួមក្នុងពិធី ថ្ងៃដើរទៅសាលាជាអន្តរជាតិ នៅ ។ ព្រឹត្តិការណ៍នេះគឺងាយណាស់ ៖ សិស្សទាំងឡាយ មាតាបិតា អ្នកអាណាព្យាបាល ព្រមទាំងបុគ្គលិកសាលា នឹងដើរទៅសាលានៅថ្ងៃនេះ ។

តាមរយៈការដើរនៅថ្ងៃនេះ នោះអ្នកនឹងជួយរំលឹកសតិសម្បជញ្ញៈ ឲ្យដឹងអំពីសេចក្តីត្រូវការដើម្បី ៖

- ✓ បង្រៀនភាពប៉ិនប្រសប់ខាងចរាចរដោយក្តីសុខសាន្ត ទៅក្មេងៗទាំងឡាយ ។
- ✓ រំលឹកមនុស្សចាស់ទាំងពួង ឲ្យបើកឡានដោយប្រុងប្រយ័ត្ន នៅពេលមកជិតបរិវេណសាលា ។
- ✓ បង្កើតនិងរក្សាទីកន្លែងប្រកបដោយក្តីសុខសាន្ត សំរាប់ឲ្យក្មេងៗដើរ ជាពិសេសការធ្វើដំណើរទៅមកពីសាលា ។
- ✓ កត់សំគាល់អំពើណាដែលយើងអាចចាត់វិធានការ ដើម្បីធ្វើឲ្យសហគមន៍របស់យើងមានក្តីមនោរម្យសំរាប់អ្នកដើរទាំងឡាយ ។
- ✓ ផ្សព្វផ្សាយពីហេតុការណ៍ ដែលក្មេងៗត្រូវការធ្វើសកម្មភាពខាងរូបកាយទៀងទាត់ ដើម្បីឲ្យមាំមួន និងមានសុខភាពល្អ ។
- ✓ ជំរុញទឹកចិត្តគ្រួសារទាំងពួង ឲ្យអរសប្បាយនិងចំណាយពេលជាមួយគ្នា តាមរយៈការដើរ ។ វាគឺជាមធ្យោបាយមួយយ៉ាងងាយ ដើម្បីឲ្យនៅមានសុខភាពល្អ ។

ចូរយើងសាមគ្គីគ្នាធ្វើការ ដើម្បីធ្វើឲ្យសហគមន៍របស់យើងមានកន្លែងមនោរម្យថែមទៀត សំរាប់ឲ្យក្មេងៗដើរ ។ អ្នកអាចជួយការនេះបាន ដោយដើរជាមួយកូនរបស់អ្នកទៅសាលាថ្ងៃ ។

ដោយនូវក្តីស្មោះស្ម័គ្រ

បើសិនជាអ្នកចង់ជួយព្រឹត្តិការណ៍នេះព្រមទាំងដើរផងដែរ សូមទាក់ទងទៅបុគ្គលមានឈ្មោះនៅខាងក្រោម ក្នុងតំបន់អ្នក ។

---

បើសិនជាអ្នក និង/ឬ កូនរបស់អ្នក បានដើរទៅមកពីសាលាជាទៀងទាត់រួចមកហើយ នោះព្រឹត្តិការនេះនឹងអរគុណ ឬទទួលស្គាល់អ្នកសំរាប់ការបានធ្វើដូច្នេះ ហើយក៏នឹងកំឡាទឹកចិត្តកូនរបស់អ្នក ឲ្យនៅតែដើរប្រកបដោយក្តីសុខសាន្ត ជាបន្តទៀត ។

បើសិនកូន ឬកូនៗរបស់អ្នកមិនដើរទៅសាលាទេ ៦ឬមិនដើរជាញឹកញាប់ទេ ៦ព្រឹត្តិការណ៍នេះនឹងជួយគេឲ្យក្លាយជាស្គាល់ច្បាស់ជាងមុន នូវផ្លូវដើរទៅមក រវាងពីផ្ទះរបស់អ្នកនិងសាលា ។ អ្នកអាចនិយាយគ្នាអំពីការគ្រោះថ្នាក់ ៦និងអំពីការល្អ ឬអ្វីដែលប្រពៃផងដែរ ៦នៅតាមផ្លូវកូនរបស់អ្នកដើរ ។

បើសិនជាអ្នករស់នៅឆ្ងាយពីសាលា ដើរទៅសាលាមិនដល់ ឬបើសិនជាមានការអ្វីមួយជាទីនាំឲ្យគ្រោះថ្នាក់ រវាងផ្ទះរបស់អ្នកនិងសាលា នោះសូមចែកដំណើររបស់អ្នកទៅជាពីរផ្នែក ។ ជាដំបូង បើកឡានឬជិះឡានបាស់ ឈប់ពាក់កណ្តាលផ្លូវទៅសាលា ។ បន្ទាប់មកក៏នាំគ្នាដើរបន្តពីទីនោះ ជាមួយកូនរបស់អ្នក ។ អ្នកអាចរៀនជាច្រើន តាមរយៈការដើរទៅសាលាជាមួយកូនរបស់អ្នក ។

**Cambodian**